សប្តាហ៍ទី
40

ប្រស្នាអំពីប្រាក់ណែន

ចៅហ្វាយបានប្រគល់ប្រាក់ទៅអ្នកបម្រើមុនពេលគាត់ចាកចេញ ចូរប្រើប្រាស់ប្រាក់ដែលព្រះជាម្ចាស់ប្រទានមកយើងឱ្យបានល្អ!

រឿងក្នុងព្រះគម្ពីរ

ព្រះយេស៊ូបានបង្រៀនពីប្រស្នាអំពីប្រាក់ណែន។ ព្រះអង្គមានព្រះបន្ទូលថា វាមានសារៈសំខាន់ណាស់ក្នុងការប្រើប្រាស់ប្រាក់ណែនដែលព្រះជាម្ចាស់ប្រទានឱ្យពួកយើងឱ្យបានល្អ។

ចៅហ្វាយបានប្រគល់ប្រាក់ឱ្យទៅអ្នកបម្រើរបស់លោក ហើយធ្វើដំណើរចេញទៅឆ្ងាយ។ អ្នកបម្រើដែលទទួលបានប្រាក់ខិតខំធ្វើការ ហើយរកបានចំណេញកាន់តែច្រើន។

ចូរយើងស្រឡាញ់ និងប្រើប្រាស់ប្រាក់ណែនដែលព្រះជាម្ចាស់ប្រទានឱ្យពួកយើងឱ្យបានល្អ។

«ដ្បិតអ្នកណាមានហើយ អ្នកនោះនឹងទទួលបរិបូណ៌ហួរហៀរថែមទៀត។ រីឯអ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមានផង»។

(ម៉ាថាយ 25:29)



វត្ថុបំណង

- ដឹងថាព្រះជាម្ចាស់បានប្រទានប្រាក់ណែនមកពួកយើង
- បណ្តុះដួងចិត្តឱ្យចេះប្រើប្រាក់ប្រាក់ណែនឱ្យបានល្អ
- បណ្តុះភាពច្នៃប្រឌិត និងបង្ហាញអារម្មណ៍តាមរយៈការធ្វើកាបូបដាក់ប្រាក់
- ទទួលបានបទពិសោធន៍នៃសេចក្តីអំណរក្នុងការចែករំលែក និងបម្រើតាមរយៈផ្សារតាឡាន់។

សម្ភារៈ


ក្រដាសពណ៌ (សម្រាប់ធ្វើកាបូប)


ក្រដាសប្រាក់ណែន (ព្រិន)


កន្ត្រៃ


ការ


ខ្មៅដៃពណ៌ហ្វឺត

របៀបធ្វើ

1. បត់ក្រដាសពណ៌ឱ្យចេញជារាងការ៉េ។
2. បត់គែមសងខាង និងផ្នែកខាងក្រោមឡើងលើ ដើម្បីធ្វើជារាងប្រអប់។
3. តុបតែងគម្របបិទបើកដោយប្រើស្ទីគ័រ។
4. បិទខ្សែរអាវ ឬស្ទីគ័រ ដើម្បីបិទកាបូប។
5. ផាត់ពណ៌ រួចកាត់ក្រដាសប្រាក់ណែន។
6. ដាក់ក្រដាសប្រាក់នៅក្នុងកាបូប។ រួចរាល់!



ការពង្រីកសកម្មភាព

- គ្រូត្រូវរៀបចំស្តង់ជាច្រើនសម្រាប់លេង
- កុមារអាចជ្រើរើសផ្នែកមួយក្នុងសកម្មភាព ហើយទទួលបានប្រាក់
- រៀបចំសម្ភារៈផ្សេងៗ ដែលអាចប្តូរជាមួយប្រាក់(តាឡាន់)បាន
- រៀនពីទឹកចិត្តនៃការចែករំលែក និងការបម្រើអ្នកដទៃ។



Tip សម្រាប់គ្រូ

- សូមប្រើប្រាស់ក្រដាសរាងចតុកោណកែង ដើម្បីឱ្យកុមារងាយស្រួលបត់ធ្វើកាបូប។
- សូមណែនាំកុមារឱ្យតុបតែងផាត់ពណ៌ក្រដាសប្រាក់ ដោយសេរីតាមដែលពួកគេចូលចិត្ត។
- សូមណែនាំកុមារឱ្យយល់ពីតម្លៃនៃការចែករំលែក និងការបម្រើតាមរយៈផ្សារតាឡាន់។
- ក្រោយពេលបញ្ចប់សកម្មភាព សូមរឿងព្រះគម្ពីរម្តងទៀត ហើយសន្យាថានឹងរស់នៅដោយប្រើប្រាស់ប្រាក់ដែលព្រះជាម្ចាស់ប្រទានឱ្យ ឱ្យបានល្អបំផុត។

